## ព្រះរាជក្រឹត្យ នស/រកត/០៦៩៩/១៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ បទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម សើត្យ សីទាលីយ៉េ ទទួលបន្ទុកបេសកកម្មអមប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងរាជរដ្ឋាភិបាល ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៤៩ អនក្រ.បក

### ស្តីពីការផ្ទេរគណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ និង អន្តរជាតិ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការចាត់តាំងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និង អន្តរជាតិ

-តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**សំរេច**

មាត្រា ១ .- ត្រូវបានផ្ទេរគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ព្រមទាំងចលនទ្រព្យ-អចលនទ្រព្យ និងក្របខ័ណ្ឌមន្ត្រីរាជការ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការ គណៈរដ្ឋមន្ត្រី ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

**អនុក្រឹត្យ លេខ ៥០ អនក្រ.បក**

**ស្តីពីការ ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា